ភ្នំពេញ ថ្ងៃទី ១៤ ខែកុម្ភៈ ឆ្នាំ២០១៧

# សេចក្ដីប្រកាសព័ត៌មាន
## ស្ដីពី
# ការផ្ដល់មូលនិធិជូនមន្ទីរពេទ្យគន្ធបុប្ផា


© រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ

ដើម្បីចូលរួមចំណែកការងារសប្បុរសធម៌ និងចែករំលែកនូវការលំបាករបស់បងប្អូនប្រជាពលរដ្ឋ មកពីតាមបណ្ដាខេត្តនានា ក្នុងការទទួលសេវាព្យាបាលជំងឺរបស់បុត្រ-ធីតាតូចៗរបស់ខ្លួន ក្នុងឱកាសទិវាបុណ្យនៃសេចក្ដីស្រឡាញ់ នាព្រឹកថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០១៧ នេះ លោកជំទាវ **ប៊ុន នារី** អគ្គនាយករងនៃអគ្គនាយកដ្ឋានពន្ធដារ និងជាប្រធានសមាគមនារីកម្ពុជាដើម្បីសន្តិភាព និងការអភិវឌ្ឍសាខាអគ្គនាយកដ្ឋានពន្ធដារ តំណាងដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តម **គង់ វិបុល** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ អមដំណើរដោយមន្ត្រីនៃអគ្គនាយកដ្ឋានពន្ធដារ បាននាំយកថវិកាចំនួន ១៦ ០០០ ០០០រៀល និង ១០ ៦៤១ដុល្លារអាមេរិក ជូនមន្ទីរពេទ្យគន្ធបុប្ផា ព្រមទាំងបានចែកជូនបាយ ៣០០កញ្ចប់ និងទឹកសុទ្ធចំនួន ១៥កេស ដល់កុមារដែលមកពិនិត្យសុខភាព ក្នុងថ្ងៃនេះផងដែរ។

លោកជំទាវអគ្គនាយករង ក៏បានជម្រាបជូនផងដែរថា មូលនិធិ និងសម្ភារៈដែលបាននាំមកជូននាឱកាសនេះ គឺជាការចូលរួមវិភាគទានរបស់ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាល



© រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ

ទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ ឯកឧត្តម-លោកជំទាវអគ្គនាយករង លោក-លោកស្រី ជាប្រធាន-អនុប្រធាននាយកដ្ឋាន ប្រធាន-អនុប្រធានសាខាពន្ធដារខេត្ត-ខណ្ឌ ព្រមទាំងមន្ត្រីរាជការពន្ធដារគ្រប់លំដាប់ថ្នាក់។ នេះជាកាយវិការដ៏ថ្លៃថ្លា ប្រកបដោយទឹកចិត្តសប្បុរសធម៌របស់ថ្នាក់ដឹកនាំ និង មន្ត្រីរាជការនៃអគ្គនាយកដ្ឋានពន្ធដារ ដែលបានចូលរួមនូវធនធានផ្ទាល់ខ្លួន និងជាការបង្ហាញនូវវប្បធម៌ នៃការចែករំលែកក្នុងការចូលរួមសម្រាលភាពលំបាករបស់មន្ទីរពេទ្យ និងបងប្អូនប្រជាពលរដ្ឋ ជាពិសេសប្រជាពលរដ្ឋដែលមានបុត្រ-ធីតាមានជំងឺ ហើយត្រូវចាកឆ្ងាយពីលំនៅដ្ឋាន មករង់ចាំទទួលការព្យាបាល។

លោកជំទាវអគ្គនាយករងក៏បានជួបសំណេះសំណាលសួរសុខទុក្ខជាមួយបងប្អូនប្រជាពលរដ្ឋ និងកុមារទាំងនោះ និងសូមជូនពរកុមារដែលមានបញ្ហាសុខភាព សូមឆាប់បានជាសះស្បើយ បានត្រឡប់ទៅលំនៅដ្ឋានវិញ ដើម្បីបន្តការសិក្សា សម្រាប់កុមារ និងសម្រាប់ឪពុក-ម្តាយ គឺបានបន្តការប្រកបអាជីវកម្មចិញ្ចឹមជីវិតឡើងវិញ៕



Foundation Children's hospital Kantha Bopha,
Dr. med. Beat Richner

Kantha Bopha
Foundation

**DONATION**

Ladies, Gentlemen: General Department of Taxation

Company :

Address :

Donation amount : 16.000.000 (...)

1.064 USD (...)

We thank you very much for your kind support
in order to save the children lives.

Phnom Penh - ~~Siem Reap~~ - Kingdom of Cambodia

Date : 14. 02. 2017

Receiver — Donor

Prof. BEAT RICHNER
Dr. DENIS LAURENT

KANTHAK BOPHA FOUNDATION

Kantha Bopha Foundation

© រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ



© រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ



© រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ